


5.93
1
ព
www.elibraryofcambodia.org

895.9321

គន្ធ ប៊ុនឈឿន

ចំណេះដឹងគ្រប់វិនាទី

ថ្ងៃទី ខែ ឆ្នាំ
2003

សូមជូន

ស្នេហ៍ដែលខ្ញុំស្រឡាញ់

(កម្រងកំណាព្យ ឧសភូនៈ)

00003926

ការបោះពុម្ពផ្សាយរបស់

បណ្ណាល័យ ឥណ្ឌូចិន

រក្សាសិទ្ធិគ្រប់យ៉ាង

ចេញផ្សាយឆ្នាំ ២០០៣

www.elibraryofcambodia.org

* ខ្មែរមានជម្ងឺ ឈឺច្រើនយ៉ាង
ជនជាតិជិតខាងឆ្ងល់នឹងខ្មែរ
ជាពូជអ្នកខ្លាំងនឹងគេដែរ
ម្តេចខ្មែរបែរជាខ្សោយជាងគេ ? ។

* គួរឱ្យឈឺចាប់ជាប់ក្នុងចិត្ត
ខ្មែរអើយគួរគិតកុំទំនេរ
ខំប្រឹងសាងជាតិឱ្យថ្កុចគេ
កុំឱ្យគេជេរថាខ្មែរ "អន់" ! ។

* គួរមើលជម្ងឺឱ្យឆាប់ជា
កុំនៅរេរាស្តីកទំរន់
ក្រោកឡើងនាំគ្នារត់ឱ្យទាន់
បើខ្មែរនៅអន់ គេ "ជាន់" ហើយ ! ។

ក.ប.ឈ

www.elibraryofcambodia.org

អារម្ភកថា

សុភាសិតចាក់ង្អុងមួយចានចែងថា "មាតុភូមិមិនដែលភ្លេចអ្នក មានតែអ្នក ដែលភ្លេចមាតុភូមិ"។ ចំពោះរូបខ្ញុំ ទោះបីឃ្លាតឆ្ងាយរហូតទៅដល់ជើងមេឃណា ក៏ប្រាគដជាមិនអាចបំភ្លេចមាតុភូមិខ្ញុំចានឡើយ ។

នៅក្នុងមនោសញ្ចេតនា ដែលនឹករលឹកដល់ស្រុកកំណើតបែបនេះហើយ (NOSTALGIE) ទើបខ្ញុំចាប់ដងចាំក្តា ខំប្រឹងតាក់តែងកម្រងកំណាព្យឈ្មោះ "បណ្តាំកវី" ដែលចានចោះពុម្ពផ្សាយរួចមកហើយ ។

ទោះបីអត្ថបទកំណាព្យទាំង ៤១ ដែលចុះផ្សាយក្នុងសៀវភៅនេះមានអត្ថបទខ្លះ ធ្វើឱ្យកំរើករញ្ជួយដល់អារម្មណ៍វិជ្ជមាន ឬអវិជ្ជមានរបស់អស់លោកអ្នកអានក្តី ក៏សូមចាត់ចុះថា · នេះគ្រាន់ជាអ្វីមួយដែលសំរាប់ជួយឱ្យបច្រាប់លោកអ្នកថា ជម្ងឺរោគានៅក្នុងសង្គមខ្មែរយើង តាំងពីអតីតមកដល់បច្ចុប្បន្ន ប្រាកដជាមានមែន ! ហើយវានឹងបន្តមានតរៀងរហូតទៅថ្ងៃអនាគតទៀត បើយើងមិនខិតខំរកថ្នាំព្យាបាល ។

ដោយគិតថា ខ្ញុំក៏ជាពលរដ្ឋខ្មែរម្នាក់ ដែលមានភាតព្វកិច្ចជួយកសាងមាតុភូមិ តាមប្រការណាដែលខ្ញុំអាចជួយចានទោះ ខ្ញុំក៏ចាំបាច់ត្រូវរំលឹកនូវ "មុខជម្ងឺ" ចាំងនេះឡើង ដើម្បីជារង្វាន់ដ៏ស្មោះត្រង់ចំពោះទិវាចោះឆ្នោតសកលនៅឆ្នាំ ២០០៣ ខាងមុខ... ។

សូមឱ្យបំណងរបស់ខ្ញុំ ចានសំរេចតាមរលកទឹកខ្មៅពនេចរនេះចុះ និងសូមឱ្យវណ្ណកមួនេះ ចានក្លាយទៅជាមិត្តដ៏មានចិត្តភក្តីបំផុត ចំពោះលោកអ្នកអានជារៀងរហូត ! ។

ក្រុងចាងកក, ថ្ងៃ ១០-១០-២០០២

គង្គ ប៊ុនឈឿន

www.elibraryofcambodia.org

សារធាន

អត្ថបទកំណាព្យ	ទំព័រ	អត្ថបទកំណាព្យ	ទំព័រ
១- ជម្ងឺខ្មែរ	5	២២- ជម្ងឺក្តិចត្រួយ	50
២- ជម្ងឺពឹងបរទេស	7	២៣- ជម្ងឺប៉ែងជើងគ្នា	52
៣- ជម្ងឺខ្វះជំនឿលើខ្លួនឯង	10	២៤- ជម្ងឺចោះឆ្មោត	54
៤- ជម្ងឺគ្រួសារនិយម	12	២៥- ជម្ងឺមិនទុកចិត្តគ្នា	57
៥- ជម្ងឺដល់ត្រើយសើយតូច	14	២៦- ជម្ងឺចាតុកម្ម	59
៦- ជម្ងឺពុករលួយ	16	២៧- ជម្ងឺគណបក្ស	61
៧- ជម្ងឺល្មោភស្រី	19	២៨- ជម្ងឺលើកជើង	63
៨- ជម្ងឺល្មោភស្រា	21	២៩- ជម្ងឺឆ្កួនក្បាលស៊ីក្បាល ឆ្កួនកន្ទុយស៊ីកន្ទុយ	65
៩- ជម្ងឺល្មោភល្បែង	23	៣០- ជម្ងឺធ្វើឈ្នាងត្រង	67
១០- លើចង់កែសង្គម !	25	៣១- ជម្ងឺខ្ចីគេ	69
១១- ជម្ងឺចាក់ស្បាត	26	៣២- ជម្ងឺផ្តាយ	72
១២- ចោរនៅស្រុកខ្មែរ	27	៣៣- ជម្ងឺចងអាឃាដ	73
១៣- ជម្ងឺលាបពណ៌គ្នា	28	៣៤- ជម្ងឺល្មោភអំណាច	76
១៤- ទំនួញស្រីខ្មែរ	29	៣៥- ជម្ងឺការិយាល័យនិយម	77
១៥- ជម្ងឺឃ្លាន	33	៣៦- ជម្ងឺរំលោភយកដី	80
១៦- ទឹកដីខ្មែរ	34	៣៧- ជម្ងឺក្រាញអំណាច	82
១៧- ជម្ងឺជឿព្រេងវាសនា	40	៣៨- ជម្ងឺរួចខ្លួន	85
១៨- ជម្ងឺស៊ីជោរ	42	៣៩- ជម្ងឺចោទគ្នាថាក្បត់ជាតិ	87
១៩- ជម្ងឺអែបអប	43	៤០- ចរណីកខ្សែង	89
២០- ជម្ងឺរំលោភសិទ្ធិ	45	៤១- ចិត្តនឹកតាមទឹកភ្នែង	97
២១- ជម្ងឺភ្លេចព្រលឹង	47		

www.elibraryofcambodia.org

ជម្ងឺខ្មែរ

(ពាក្យ ៣)

* ជម្ងឺខ្មែរ ខ្មែរត្រូវឈល់ ស្គាល់ឱ្យច្បាស់
ហើយរហ័ស ធ្វាស់ប្តូរថ្នាំ ធ្យឱ្យត្រូវ
កុំបណ្តោយ ឱ្យរលួយ កើតដង្កូវ
ទុកយូរទៅ ក្លាយជំងៃ .មហារីក ។

* ជម្ងឺខ្មែរ កើតតាំងតែ ពីយូរហើយ
ខ្មែរគ្មានស្បើយ ល្ហើយឈឺចុក ចាប់ពន់ពេក
កើតតកូន ពូនតចៅ ក្តៅស្អុយបែក
ខ្មែរថ្ងូរស្រែក ភ្នែកស្ទើរលៀន គ្មានស្រាកស្រាន្ត ។

* ជំងៃខ្មែរ កើតព្រោះខ្មែរ ខ្វះស្មោគគ្រោក
ទើបមេរោគ ជោកជាមនៅ ខ្មៅជាប់ច្រាណ
ជំនាន់ណា ក៏ជំងៃ ខ្មែរនៅមាន
ដូចអាកៀន ល្បៀនជាប់ក្តឹក តែមិនឡើង ។

* ជំងៃខ្មែរ កើតព្រោះខ្មែរ ខ្វះលោភលន់
ហ៊ានលួចបន់ ជ័យភ័ណ្ឌជាតិ តាមទំនើង
អាងអំណាច អាចជីកកាប់ តាស់រំលើង
លេបទាំងភ្លើង ដូចឈើងទាម ឈាមគ្មានស្បើយ ។

www.elibraryofcambodia.org

* ជម្ងឺខ្មែរ មិនត្រឹមតែ រឿងបុណ្យស័ក្តិ
ទោះមាសប្រាក់ ដាក់ពេញទូ ប៉ុណ្ណឹងហើយ
នៅជិះជាន់ រំលោភសិទ្ធិ ឥតកោះត្រើយ
ខ្មែរគ្មានស្បើយ ល្ហើយល្ហែពី ទុក្ខកង្វល់ ។

* ជំងៃខ្មែរ ស៊ីតាំងតែ ពីចុងឈើ
ទើបរង្គើ ញ័ររញ្ជួយ ចុះដល់គល់
អ្នកក្រោមឃើញ អ្នកលើស៊ី ចាក់ច្រាស់ហល់
ក៏ប្រមូល កាកសំណល់ ស៊ីដែរ ទៅ ! ។

* ជម្ងឺខ្មែរ តហ្សរហែ ជាទម្ងាប់
គួរប្រញាប់ ធាប់ព្យាបាល កុំទុកនៅ
លាងសង្គម កុំឱ្យមាន សល់ឥង្គារ
នាំអាស្រូវ នៅក្នុងចិត្ត ឥតរសាយ ។

១០-០៦-០១

គបលប គបលប គបលប

www.elibraryofcambodia.org

២. ជម្ងឺពីចបរទេស

(ចាក្យ ៧)

* ព្រះចាទអង្គខ្ជិងទ្រង់ឈ្វេងយល់
ខ្លាចសៀមធ្វើកលយកទឹកដី
រុមទាំងអណ្តាមយួនអប្រិយ៍
ទើបទ្រង់រំពៃពីងពាភាំង ។

* ឱ្យមកជួយរៀបចំកម្ពុជា
ការពារអក្សាភាជបល្ល័ង្ក
ព្រោះពេលនោះខ្មែរខ្សោះកម្លាំង
ខ្វះចំពតតាំងនឹងបច្ចា ។

* មួយពាន់ត្រាំបីរយហុកបី
កូនខ្មែរប្រុសស្រីចាំសាវតារ
ពាភាំងចូលជាន់ដីខេមរា
នាមជាអាណានិគមសុទ្ធ ។

* ជម្ងឺពីងតេ ជាចម្លាប់
មានហូរហែជាប់មិនចេះផុត
សង្គ្រាមរាជវង្សឥណ្ឌីមម្តង
ស្តេចខ្មែរតែងរត់ទៅពឹងតេ ។

www.elibraryofcambodia.org

* ពីងម្តងកាត់សងអោយទឹកមី
ជាប្រពៃណីមិនខានទេ
បើគ្មានចំណេញអ្វីវល់គេ
គេមិនជួយទេ ចាំឱ្យស្លាត់ ។

* ម្តងយួនម្តងសៀម អង្គៀមឆ្នឹង
ខ្មែរស្គមរយឹងលែងធំធាត់
កម្ពុជាក្រោមដីកំសត់
ចាភ៉ាងចែងចាត់កាត់ឱ្យយួន ។

* ចាភ៉ាងចូលមកចំណេញស្តេច
តែរាស្ត្រលង់លិចខាតផ្ទួនៗ
ពន្ធអារអាករនឹមជាប់ខ្លួន
ចាភ៉ាងឱ្យយួនត្រួតខ្មែរទៀត ។

* ចាភ៉ាងនាំមកន្ទួរបបៃ
លុតក្រាបអែបអបលេបមានស្នៀត
ស៊ីកសៀតឆ្មៀតពងដូចត្រីងៀត
ខ្មែរងងសម្លាចរបូចមីថ្មី ។

www.elibraryofcambodia.org

* ជម្ងឺពីងគេ មានតែខាត
ចូរចាំភ្លុំឃ្លាតខ្មែរប្រុសស្រី
ប្រវត្តិប្រាប់ថា ខ្មែរអស់ជី
ព្រោះតែទ្រឹស្តីពីងបរទេស ! ។

Super Good

១៥-០៦-០៩

ចប់ ចប់ ចប់

www.elibraryofcambodia.org

៣. ជម្ងឺខ្ទះជំនឿលើខ្លួនឯង

(ចាក្យ ៨)

* ជម្ងឺខ្ទះជំនឿលើខ្លួនឯង
នាំឱ្យនឹកក្រែងចារម្ដងជានិច្ច
ធ្វើអ្វីតែងតែពឹងគេមិនភ្ញាច
ឃើញគេជាពេជ្រខ្លួនឯងសំណរ ។

* ជម្ងឺមិនជឿខ្លួនឯងថាអាច
នាំឱ្យនឹកខ្លាចធ្វើមិនបានល្អ
បង្អន់ជាតិឯងបង្ហាប់វប្បធម៌
បែរជាគាំទ្រវប្បធម៌ដទៃ ។

* ពេលណាក៏ថាខ្មែរមិនដល់គេ
គួរស្ដាយម្ល៉េះទេខ្មែរភ្ញាច់ដៃ
វប្បធម៌ដូចពេជ្រភ្ញាច់ថែកែច្នៃ
មិនឱ្យដៃព្រលឹងជាតិឯង ។

* បើខ្ទះជំនឿគឺខ្ទះឆន្ទៈ
ដប់ពីរលានៗនាក់ចិត្តរវូចផ្សែង
គ្មានគោលលំនឹងពឹងលើខ្លួនឯង
ភ្ញាច់មើលដើមត្រែងអាចឈ្នះព្យុះបាន ។

www.elibraryofcambodia.org

* បើខ្ទុះជំនឿតឹអស់សង្ឃឹម
ស្លូចម្ទេយទូរទឹមចាំទីអវសាន្ត
កំប៉ាត់ជម្ងឺនេះចេញឱ្យបាន
ទើបខ្មែរគ្រប់គ្រាណបានលឿនទៅមុខ ! ។

៣០-០៦-០១

គបណ គបណ គបណ

www.elibraryofcambodia.org

៤. ជម្ងឺគ្រួសារឆៃយម

(ពាក្យ ៤)

* ចារាំងនោះណា ទុកឱគត្រួសារ ឱយមឱ្យខ្មែរ
ជាកេរមតីក អាក្រក់ឥតល្ហែ ទម្លាប់ឱ្យខ្មែរ
គិតតែផ្តាល់ខ្លួន ។

* រាប់តែញាតិមិត្ត សាច់សារលោហិត ស្អិតដូចក្រមួន
ឯអ្នកដទៃ មិនមែនញាតិខ្លួន បែរជាគុំគួន
ជួនសួរប៉ិនន្តា ។

* ទោះអ្នកអភ័ព្វ ដេកអត់ចាយស្ងាប់ ក៏គ្មានទីកន្លែង
គិតតែត្រួសារ អញមានទ្រព្យា រស់ស្រួលហ៊ីហារ
គឺរួចគ្មាហើយ ។

* សុទ្ធតែអួតថា ស្មោះនឹងខេមរា ពិតពុំកន្តើយ
សុខទុក្ខរួមគ្នា ត្រប់ត្រាកៀកកើយ តែមិនពិតឡើយ
ថាឱ្យស្លែច ។

* ជម្ងឺត្រួសារ និយមនេះណា លាក់កប់គំនួច
មាត់ធ្យឹងចិត្តផ្សែង លបលេងលាក់ល្ហួច គិតតែមួយរួច
ក្រប្លេចយកសុខ ។

www.elibraryofcambodia.org

* ជម្ងឺនេះណា៎ ធ្វើឱ្យខេមរា យល់គ្នាដោយមុខ
  រីសអើងម៉ើលងាយ ពេបជ្រាយចាប់ចុក ដូចហាង្សនិងកុក
  ចុកចិត្តមិនបាន ! ។

១៦-០៧-០១

ឥឥឥ ឥឥឥ ឥឥឥ

www.elibraryofcambodia.org

៥. ជម្រើសត្រើយ សើយគូថ

(ពាក្យ ៣)

* តើអំណាច គឺជាអ្វី តាមន័យពិត ?
អ្នកខ្វះគិត ថាអំណាច ជាអាជ្ញា
មានអំណាច អាចសម្លាប់ កាប់អ្នកណា
ចង់ប្រហារ បានតាមចិត្ត ឥតកោតក្រែង ? ។

* មនុស្សលោក តែងតែចង់ បានអំណាច
ព្រោះវាអាច ឱ្យគេខ្លាច កោតស្ងប់ស្ងែង
ទើបខំប្រឹង ទាំងទទឹង ទិសឥតក្រែង
ជាន់តែឯង ឱ្យតែបាន អំណាចនោះ ។

* ខ្វះសុខចិត្ត ធ្វើបូកថោក ដូចពួកស្ងួម
លើកដៃសូម ឆ្កឹះសំពះ តាមទូរទស្សន៍
ពេលចោះឆ្មោត ធ្វើមុខស្លូត គួរស្រណោះ
សំពះអស់ តាំងពីក្មេង ក្នុងអង្រឹង ។

* ព្រោះដឹងថា អំណាចជា របស់រាស្ត្រ
ទើបសំពះ សុំង៉ូចៗ ដូចក្លួនជឹង
ស្រក់ទឹកមាត់ ឃ្លានអំណាច ធ្វើភ្នែកស្ងឹង
អស់ដំឡឹង មាសប៉ុន្មាន ក៏មិនស្កាយ ។

www.elibraryofcambodia.org

* មានអំណាច អាចនាំមក នូវលាភជ័យ
ជាទ្រឹស្តី បើចង់បាន ត្រូវហ៊ានចាយ
ទើបប្រមូល អស់កេរឱ អស់កេរម្តាយ
លក់ចំណាយ ទិញសន្ទឹក ឆ្មោតពីរាស្ត្រ ។

* ខ្លះភ្ញែចខ្លួន ដូចក្រមួន ត្រូវកំដៅ
ចន់ជ្រាយនៅ ចំពោះមុខ ប្រាក់ ឬ មាស
ឆាប់ចន់ចិត្ត អាណិតគេ ដៃលសំពះ
ទើបគួសវាស ឈ្មោះឱ្យគេ ឥតសង្ស័យ ។

* លុះពេលបាន អំណាចក្តាប់ ត្រប់បែបយ៉ាង
លោកតំណាង រវល់ណាស់ ទាំងយប់ថ្ងៃ
ពាក្យសន្យា ថាធ្វើផ្លូវ ធ្វើស្ពានថ្មី
ប្រែគ្មានន័យ អ្វីសំរាប់ ម្ហាស់ឆ្មោតឡើយ ។

* លោកតំណាង អាងអំណាច លែងខ្វាចរាស្ត្រ
ឈប់សំពះ ឈប់អង្វរ ដូចមុនហើយ
ព្រោះលោកមាន អភ័យឯក- សិទ្ធិជុតត្រើយ
រាស្ត្រឥតស្បើយ លោកដល់ត្រើយ សើយគួចដាក់ ! ។

០៥-០៨-០១

ចប់ ចប់ ចប់

www.elibraryofcambodia.org

៦. ជម្ងឺពុករលួយ

(ពាក្យ ៥)

* ជម្ងឺពុករលួយ
ជារោគអួយ សំរាប់ខ្មែរ
មានកើតតហ្សរហែ
តាំងតែពីរាជ្យចាភាំង ។

* របបអង្គុយតុ
បង្កទុក្ខកង្វល់ខ្លាំង
ជាក្តែលដែលចាភាំង
រៀបតែងតាំងទុកឱ្យខ្មែរ ។

* កញ្ឆា ស្រា អាភៀន
ឆីក ជក់ ញៀន លៀនភ្នែកត្រែ
ចារ បន ត្រាន់លំហែ
មន្ត្រីខ្មែរ ឈ្លក់វង្វេង ។

* ច្រៀងរាំតៀកកេះតៀវ
អោបស្រើបស្រៀវតាមបទភ្លេង
ញ៉ែរញ៉ាក់ហក់កញ្ឆេង
ខ្មែរវង្វេងតាមចាភាំង ។

www.elibraryofcambodia.org

* មន្ត្រីខ្មែរសប្បាយ
ភ្ជុស្តេខ្វល់ខ្វាយកើតទុក្ខខ្លាំង
លោកធំខ្ញុំចាភាំង
ឈ្លក់ញៀនខ្លាំងតាំងប្រវ័ញ្ច ។

* ឈ្លក់ធ្លាញ់ ឈ្លក់ហ៊ីហារ
ខំស្រវារ កន្លែងខ្លាញ់
ឱ្យបានច្រាក់ចំណេញ
គ្រាន់បំពេញមហិច្ឆិតា ។

* តមកជាទម្លាប់
ជាប់ក្នុងសង្គមខេមរា
ឱ្យតែអ្នកធ្វើការ
តែងច្រថ្នាលាភសក្ការៈ ។

* សំណែនសែនសំណូក
បានធ្វើលោកស្មូកឡើងស័ក្តិ
ងាយស្រួលរកមាសច្រាក់
ជាទស្សនៈមន្ត្រីខ្មែរ ។

HUN SEN LIBRARY R.U.P.P.
www.elibraryofcambodia.org

* រលួយពុកដល់ឆ្អឹង
ម្នាក់ៗប្រឹងបួមគ្មានល្ហែ
ជាតិស្គមគ្មានថ្នាំកែ
ព្រោះតែខ្មែរខ្វះបំពាន ។

* ខ្វះលួចលក់ឈើព្រៃ
ធ្វើសេដ្ឋីសល់វាល់លាន
ខ្វះទៀតលក់ថ្នាំញៀន
មានប្រាក់ធ្វើនៅបរទេស ? ។

* ជាតិក្រ សូមទានគេ
ឯមេៗ ស៊ីស្តើរប្រេះ
គួរឈឺចាប់អ្វីម្ល៉េះ
ជម្ងឺនេះ មើលមិនជា ! ។

០៣-០៩-០១

ឥឡូវ ឥឡូវ ឥឡូវ

www.elibraryofcambodia.org

៧. ជម្ងឺល្មោភស្រី

(ពាក្យ ៤)

* ចាស់ហើយមិនគិត ចង់តែស្នេហ៍ស្និទ ជាមួយស្រីក្មេង
លបលាក់ចិញ្ចឹម ទុកគ្រាន់បន្ទែង មួយនៅព្រែកឯង
មួយនៅគៀនស្វាយ ។

* ខ្លាចជំទាវដឹង លោកតាខំប្រឹង ដើរកលឧបាយ
លួចឆ្នក់ដូចឆ្មា លបចេញនាយអាយ ព្រោះចង់សប្បាយ
មុនចូលរណ្តៅ ។

* លោកតាវង្វេង ឆ្ងាញ់តែក្មេង។ យកធ្វើថ្នាំប៉័ូវ
កិបកេងលុយកាក់ លាក់ច្រើនហោចៅ ទុកទិញប្រេងម្សៅ
ឱ្យពៅស្រីស្នេហ៍ ។

* ជម្ងឺល្មោភស្រី មានច្រើនពេកក្រៃ ពេញជីស្រុកខ្មែរ
ក្រមុំជនបទ កំសត់ក្តាមស្រែ ត្រូវពួកចៅកែ
ទិញភ្ញកូព្រហ្មចារ្យ ។

* គេចង់បានតែ ក្មេងស្រីស្រុកស្រែ ស្ទើរមិនគ្រប់ការ
យកមកចិញ្ចឹម ធ្វើជាអាហារ លុះឆ្អែតកាលណា
ធ្វើពេស្យាទៀត ។

www.elibraryofcambodia.org

* ចាស់ក្បាលទំពែក នៅតែឃ្លានស្រេក ត្រេកមិនចេះឃ្លាត
បន្ទែបន្ទំ ធ្សំលួចលុយជាតិ លោកតាត្រីងៀត
ឆ្លៀតចិញ្ចឹមស្រី ។

* ចាស់ហើយគួរតែ លាងចិត្តកែប្រែ ពីកាមលោភីយ៍
នាំខ្លួចកិត្តិយស ព្រោះរឿងអប្រិយ៍ ហ៊ានធ្វើអ្វី។
ដើម្បី "សាច់ល្មើយ"! ។

១០-១០-០១

ចប់ចប់ ចប់ចប់ ចប់ចប់

www.elibraryofcambodia.org

៨. ៨ម្ងីឈ្មោតស្រា

(ខាក្យ ៤)

* នៅទីក្រុងខ្មែរ ឃើញមានហូរហែរ តែហាងលក់ស្រា
សម្បុរណ៍អ្នកផឹក ស្រវឹងម្ល៉ូម្ល៉ា ខ្មែរឆ្គួតនឹងស្រា
មិនតិចលាននាក់ ។

* មុនផឹកល្អជា សុភាពបូកពារ គួរភប់រាក់ទាក់
លុះពេលស្រវឹង ប្រែក្លាយជាយក្ស ហក់លោតទាត់ធាក់
មិត្តភ័ក្តិគ្នាឯង ។

* អ្នកកាន់អំណាច ខ្វះស្រវឹងកាច ចាញ់ចោះឥតក្រែង
ល្មើសបំពានច្បាប់ សម្លាប់គ្នាឯង ខូចខ្លួនទាំងក្មេង
បើវង្វេងស្រា ។

* គ្មានចំណេញសោះ ចានត្រឹមខូចឈ្មោះ អាប់យសសក្តា
ស្រវឹងជានិច្ច ភ្លេចរឿងខេមរា ឥតឃើញតែស្រា
ធ្វើការមិននឹង ។

* សង្គមប្រមឹក ខ្វះក្បាលស្មោធស្តឹក ភ្លេចអស់ព្រលឹង
គេធ្វើឱ្យខ្មែរ គិតតែស្រវឹង គួរតែខ្មែរប្រឹង
លះបង់ចោលចេញ ។

www.elibraryofcambodia.org

* ស្រីឯងដល់ណា ពេលនេះខេមរា កំពុងទោម្នេញ
យើងធឹកសប្បាយ នៅក្រុងភ្នំពេញ ឯនៅស្រែវិញ
មានអ្នកដាច់ពោះ ! ។

១០-១០-០៩

គបឈ គបឈ គបឈ

www.elibraryofcambodia.org

៩. ជម្រើសល្អោតល្បែង

(ពាក្យ ៩)

* សង្គមឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា
ឆ្កួតធំមួយទៀត គឺល្បែងពាលា ធ្វើឱ្យកម្ពុជា
វេទនាកន្ធង ។

* ជល់មាន់ភ្នាល់លុយ ល្បែងឆ្នោតកន្ទុយ បៀរចាំអាចាំង
កាត់តេយីយ៉ាត់ ស៊ីសឹកបៀរតង បៀរផ្តាច់ទាយខ្នង
ចាក់ម្តងសងដប់ ។

* ល្បែងតូចតាចនេះ ជួនកាលប៉ូលិស ប្រមូលដេញចាប់
តែកាស៊ីណូ បើកលេងមានច្បាប់ គ្មានអ្នកហ៊ានចាប់
ហ៊ានធ្វើអ្វីឡើយ ។

* អ្នកញៀននឹងល្បែង ខិតខំស្វះស្វែង លេងពុំកន្តើយ
ជួនកាលលេងឈ្នះ រីករាយឥតត្រើយ ពេលណាចាញ់ហើយ
ឥតស្បើយលិចលង់ ។

* កាស៊ីណូណាគ្លា នៅលើនាវា ក្នុងទឹកមេគង្គ
ហូលីដេចាត់រួប ពីកណ្តាលក្រុង ទៅកើតយ៉ាងខ្លង់
នៅព្រំដែនថៃ ។

www.elibraryofcambodia.org

* កាប់ឈើងអូរស្ទាច់ កាស៊ីណូក៏លេច រូបរាងជាថ្មី
អ្នកលេងចំរុះ មានទាំងខ្មែរ-ថៃ ខ្មែរចាញ់រាល់ថ្ងៃ
រឹងរៃចងក ។

* សេដ្ឋកិច្ចទន់ខ្សោយ ចានកាស៊ីណូជួយ គ្រាន់រស់បន្ត
ល្បែងនាំឱ្យចាត់ បង់ទ្រព្យគុណធម៌ សង្គមវិកវរ
រាស្ត្រក្រមិនចប់... ។

០៥-១១-០១

ឥឥឥ ឥឥឥ ឥឥឥ

www.elibraryofcambodia.org

១០. បើចង់កែសង្គម !

(ពាក្យ ៧)

* ខ្មែរ បើចង់កែសង្គមបាន
ខ្មែរ ត្រូវតែហ៊ានផ្តល់គំនិត
ខ្មែរ កុំញញើតទាំងឆ្ងាយជិត
ខ្មែរ កុំភ័យភិតខ្លាចឱ្យសោះ ! ។

* ខ្មែរ ត្រូវយល់ថាមាតុភូមិនេះ
ខ្មែរ ត្រូវត្រិះរិះឱ្យច្បាស់លាស់
ខ្មែរ ជាម្ចាស់កម្ពុជាទាំងអស់
ខ្មែរ កុំយល់ខុសស្លប់ជាតិឯង ។

* ខ្មែរ កុំមើលងាយថាខ្មែរអន់
ខ្មែរ កុំទំរន់ទន់ជួចជ្រែង
ខ្មែរ ត្រូវតាំងចិត្តឱ្យខែងរឹង
ខ្មែរ ត្រូវស្គាល់ខ្លួន ឯងឱ្យច្បាស់ ។

* ខ្មែរ តើធាតុពិតជាអ្នកណា ?
ខ្មែរ មកពីណា ទៅណាខ្លះ ?
ខ្មែរ ត្រូវតែស្គាល់ប្រវត្តិសាស្ត្រ
ខ្មែរ គឺជាម្ចាស់វាសនាខ្មែរ ! ។

៣០-១១-០១

www.elibraryofcambodia.org

១១. ជម្ងឺចាក់ស្បាត

(ពាក្យ ៧)

* ធ្លាប់ឃើញប៉ុលពតចងសម្លាប់
ធ្លាប់ឃើញគេចាប់ទៅពិឃាត
ធ្លាប់ត្រូវគ្រាប់បែកគប់ប៉ើងខ្ពាត
ខ្មែរសែនចាក់ស្បាតដល់សព្វថ្ងៃ ។

* ពេលជួបអ្នកធំមានអំណាច
អ្នកតូចក៏ខ្លាចឈរអោបដៃ
បុកពោះលាន់ខ្ពំរញ៉ៃរភិតភ័យ
មិនហ៊ានហ៊ារស្តីខ្លាចមានទោស ។

* ចង់តវ៉ាស្តីតែមិនហ៊ាន
សុខចិត្តអៀនប្រៀនអោនមុខចុះ
ពេលឃើញអ្នកធំនិយាយខុស
មិនហ៊ានបន្ទោសខ្លាចគេស្អប់ ។

* អ្នកធំជោមស្អុយថាក្រអូប
ប្រើងឈរបីតស្អែបថាទឹកអប់
ជម្ងឺចាក់ស្បាតតាមតោងជាប់
បើអ្នកធំសួរ "តីចាត់ខ្លួន ?" ។

www.elibraryofcambodia.org

១២. ចោរឆៅស្រុកខ្មែរ

(ពាក្យ ៧)

* ចោរ រកស្រុកខ្មែរមានច្រើនយ៉ាង
ចោរ កាចចោរកាងអាងកាប់ចាក់
ចោរ ធំចោរតូចលួចតាមថ្នាក់
ចោរ សោរចោរសំក្តិពាក់ល្បើស្លា ។

* ចោរ លួចម៉ូតូចោរលួចម្សាន
ចោរ លួចឆ្នាំងចានលក់ធីកស្រា
ចោរ អានប៊ីយ៉ូអានវីម្សា
ចោរ កាប់ព្រឹក្សាលក់ធ្វើអាន ។

* ចោរ លួចនាំចូលកាកសំណល់
ចោរ លក់ថ្នាំពុលលក់គ្រឿងញៀន
ចោរ លក់កញ្ឆាលក់អាភៀន
ចោរ ស្មេរចោរស្មៀនលួច Effectif ។

* ចោរ ល្អិតចោរល្មោចលួចឆ្នាំងចាន
ពេល គេចាប់បានវាយបែកខ្ទិះ
ចោរ កាលីវេលើមានម្សានជិះ
ចោរ ក្បត់ជាតិនេះ រួចរហូត !. ។

www.elibraryofcambodia.org

១៣. ជម្ងឺលាបពណ៌គ្នា

(ពាក្យ ៥)

* ជម្ងឺលាបពណ៌គ្នា
នៅកម្ពុជាមានមិនចប់
តគ្នាជាទម្លាប់
បើគេស្អប់អ្នកណាម្នាក់ ! ។

* ចោទថាក្រហម ខៀវ
ក្មានស្រាវជ្រាវឱ្យជាក់លាក់
បែងចែកជាពួកបក្ស
ល្ងចកាប់ចាក់ចាញ់ប្រហារ ។

* គួរឱ្យខ្លាចអ្វីម្ល៉េះ
ជម្ងឺនេះកាចអស្ចារ្យ
ខ្លះត្រូវគេប្រហារ
ហើយចោទថាជាអាបធ្មប់ ។

* ឈាមខ្មែរពណ៌តែមួយ
ហេតុម្តេចឡើយប្តូរពណ៌ត្រប់
យកថ្ងៃ ធ្វើជាយប់
ខ្មែរត្រូវឈប់ លាបពណ៌គ្នា ! ។

៣០-១២-០១

www.elibraryofcambodia.org

១៤. ទំនួញ្ញាស្រីខ្មែរ

(ពាក្យ ៨)

* ទំនួញ្ញាស្រីដ៏ខ្មែរ ក្រោមដែនទោច
ធ្លួញមំផ្សាខ្លោចថ្លូរថ្លុចញាប់ញ័រ
ពាំតាំងតែពីសម័យអង្គរ
ស្តាយកេរវប្បធម៌ដែលជាត់បង់ទៅ ។

* ដោយអានខ្មែរក្សត់ចិត្តពាលឃាតករ
ធើពាក្រុងអង្គរ ចាញ់ដែសត្រូវ
គេប្រមូលយកកេតនៈឆ្ពិនឆ្លៅ
ពីកព័ណ្ឌនទៅធ្វើរបស់វា ។

* មេរៀនខ្មែរក្សត់ជូរចត់ពេកក្រៃ
ធ្វាក់ជាប់បាបូទ័យស្រីខ្មែរគ្រប់គ្នា
ក្រុងអង្គរអើយ ! ខ្ញុំសូមក្រាបលា
ទៅសាងភារនៅលែងៃកថ្មី ។

* លែងៃការងអាំរៀបចំជុំវិញ
បន្តាយពោរពេញដោយព្រៃបូស្សី
ច្រើនជាន់ច្រើនជួរចូលមិនចានអី
សាងជាតិជាថ្មី ក្រោយថ្ងៃអង្គរ ។

www.elibraryofcambodia.org

* សៀមឃើញលង្វែកស្រែកឃ្លានចង់ចូល
ព្រើម្បីប្រមូលកេតនៈវប្បធម៌
តែខ្មែរមួលមីរសាមគ្គីក្រោកឈរ
ការពារវប្បធម៌បន្ទាយលង្វែក ។

* ទំនួញស្រីខ្មែរនៅតែលាន់ឮ
ព្រោះស្រីខ្មែរឈឺចុកចាប់ពន់ពេក
សៀមឆ្លាតចាញ់ច្រាក់ផ្លូងចូលលង្វែក
ខ្មែរល្ងង់ឃ្លានស្រែកកាប់ព្រៃបូស្សី ។

* កាប់អស់សៀមផ្ទោះចូលបំផ្លាញខ្ទេច
ប្រមូលមាសពេជ្រកេតនៈល្បាញល្បី
ខ្មែរស្រុតម្តងទៀត ស្ទើរក្រាបដល់ដី
ចាត់បង់ស្មារតី ផែនដីលិចលង់ ។

* មេរៀនអង្គរ បន្ទរលង្វែក
ស្រីខ្មែរទឹកភ្នែកមកដល់ខត្តង្គ
ចារឹងចូលត្រួតខ្មែរធ្លាក់អន្ទង់
ដួចកុកជាប់ជង់ជិតមួយរយឆ្នាំ ។

www.elibraryofcambodia.org

* ផុតពីឧត្តុង្គមកដល់ភ្នំពេញ
ចាភាំងចាកចេញខ្មែរផុតគ្រោះកម្ម
បុណ្យកម្ពុជា រីកស្រស់ស្រងាំ
បានជិតម្ភៃឆ្នាំខ្មែររងកម្មថ្មី ។

* រាជានិយមត្រូវរំលំផ្តួល
មាតុភូមិប្រែប្រួលជារដ្ឋសើរ
បានជិតច្រាំឆ្នាំកម្មតាមប្រល័យ
ក្នុងកណ្តាប់ដៃ ប៉ុលពតពេជ្ឈឃាត ។

* របបបូស្សាប្រហារជាតិឯង
នាំឱ្យយួនក្លែងចូលមកឆ្លៀតឆ្លៀត
ធ្វើជាជួយខ្មែរតាមខ្សែត្រីងៀត
ខ្មែរក្រៀមក្រំទៀតរិះចាត់បង់ដី ។

* ទំនួញស្រីខ្មែរគ្មានល្ហែស្រាកស្រាន្ត
ក្រោយមក ទើបបានរួមគ្នាជាថ្មី
សាងសន្តិភាព ចោះឆ្នោតកៅបី
របបសើរធិបតេយ្យ[1] ពហុបក្ស ។

១- របបសើរប្រជាធិបតេយ្យ

បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R.U.P.P. www.elibraryofcambodia.org

* ជម្ងឺពីងគេនៅតែមិនឃ្លាត
ម្តងហើយម្តងទៀតព័ទ្ធវាងទៀងជាក់
ពេលខ្មែរឈ្លោះគ្នារត់ទៅពឹងពាក់
ហៅវែកក្លឹម្រាក់ អតីតបច្ចា ។

* ពេលស្រុកយើងលិច ស្រុកគេអណ្តែត
នេះជាផលហេតុ មានក្នុងសាវតារ
ចំនួញស្រីខ្មែរ គ្មានល្ហែថ្នូរថា
ពេលនេះសាវតារ ជាន់ដានចាស់ហើយ ! ។

០៣-០១-០២

តបណ តបណ តបណ

www.elibraryofcambodia.org

១៥. ជម្ងឺឃ្លាន

(ពាក្យ ៤)

* ព្រោះតែរឿងឃ្លាន មនុស្សខ្វះបំពាន រកស៊ីខុសច្បាប់
ចានឆ្អែតពោះហើយ ថែមចង់មានឆាប់ បើរកស្របច្បាប់
មិនឆាប់មានទេ ។

* ឃ្លានម្ហូបចំណី ឃ្លានស្រាឃ្លានស្រី ឃ្លានយកប្តីគេ
ឃ្លានបុណ្យឃ្លានស័ក្តិ ឃ្លានធ្វើតួកជេរ ឃ្លានចង់ធ្វើមេ
ឃ្លានជេរម្តាយប្តី ។

* ឃ្លានប៉ុន្មាននេះ មិនស្មើរវិសេស ដូចឃ្លានបែបថ្មី
គឺឃ្លានកាប់ឈើ លក់ធ្វើសេដ្ឋី ឃ្លានធ្វើមន្ត្រី
ឃ្លានលួចដីរាស្ត្រ ។

* ឃ្លានសន្ធឹកឆ្មោត មិនដូចឃ្លានពោត បុឃ្លានឆាម្រេះ
ឃ្លាននេះឃ្លានខ្លាំង ស្មើរដាច់ក្រពះ សុខចិត្តលក់ផ្ទះ
ឱ្យតែចាត់ឃ្លាន ។

* ជម្ងឺឃ្លានស្រែក អានច្រើនពន់ពេក នឹកគួរឱ្យអៀន
តែមានឃ្លានមួយ រលួយជាប់ត្រចៀក គឺជម្ងឺឃ្លាន
ធ្វើធំរហូត ! ។

www.elibraryofcambodia.org

១៦. ទឹកដីខ្មែរ

(ពាក្យ ៣)

* ទឹកដីខ្មែរ បើកុំតែ ឈ្លោះទាស់គ្នា
ម៉្លេះមុខជា បានឡើងខ្ពស់ ឈ្លោះល្បាញល្បី
ព្រោះខ្មែរជាប់ ពូជពង្សអ្នក សាងច្រាង្គជ័យ
មានស្នាដៃ ខាងវប្បធម៌ និងសិល្បៈ ។

* បើខ្មែររួម សាមគ្គីគ្នា ក្នុងសន្តិ (១)
កុំបែកប្រេះ រលេះប្រាណ ដូចស្ពានចាក់
កុំទាស់ទែង ខ្វែងគំនិត បែកពួកបក្ស
នោះខ្មែរជាក់ ជាបានរស់ ខ្ពស់រុងរឿង ។

* ឱ កម្ពុជា ជាដីដែន សែនស្រណោះ
ខ្ញុំអាលោះ ស្មោះនឹកអ្នក ដែលព្រាត់ឆ្ងាយ
នឹកឃើញបឹង ស្ទឹងទន្លេ វែងអន្លាយ
ខ្ញុំនឹកស្ដាយ ធនធានធម្ម- ជាតិក្រៃណា ។

* ទន្លេសាប ព្រៀបដោយត្រី ជាប្រចាំ
មានខេត្តច្រាំ ចាំទទួល ផលមច្ឆា
ក្រុងប៉ៃលិន ដែនមុជ្ជលិន្ទ មរតកដា
ស្បងរចនា ជារតៈ (២) នៈមណ្ឌល ។

(១)- សន្តិភាព ។ ២- រតៈ-តៈ-នៈ ។

www.elibraryofcambodia.org

* ចាត់ដំបង បន្ទាយជ័យ[1] ល្បីខាងស្រូវ
ពោធិសាត់នៅ មានថ្នូរធ្លាក់ លួពេកសល់
ភ្នំក្រវាញ ក្រវ៉ាន់រ័ត្ន បពិតពល
ជាមណ្ឌល ឈើក្រអូប ស្រូបមិនណាយ ។

* ស្រុកចាកាន វិមានថាន អ្នកឧកញ៉ា
គីអ្នកតា ឃ្លាំងមៀងឯក អគ្គពណ្ណរាយ
ហ៊ានបូជា ជន្មជីវិត ឥតសោកស្ដាយ
និម្មិតកាយ កៀរទ័ពខ្មោច រាប់ម៉ឺនសែន ។

* កំពង់ឆ្នាំង ក្រាំងជីវិត នាងកង្រី
ជាទឹកដី អ្នកស្នងឆ្នាំង ដីជាប់ណែន
កំពង់ធំ ជម្រំស្នេហ៍ ជំទាវស្រែឣ្យ
ជាដីដែន តេជោយ័ត តេជោមាស ។

* ក្រុងអង្គរ បវរជ័យ ដីសៀមរាប
ល្បីជ្រួតជ្រាប ពេញភពដែន ដែនសន្និវាស
ភ្នំគូលេន ទឹកជ្រោះធ្លាក់ ត្រជាក់ណាស់
អង្គរធំព្រះ[2] ចូលនិព្វាន ថានមនោរម្យ ។

១- បន្ទាយមានជ័យ ។ ២- ព្រះអង្គធំ ។

www.elibraryofcambodia.org

* ក្រុងភ្នំពេញ មាត់ទន្លេ ចតុមុខ
កប់លាក់ទុក អតីតកាល សែនក្រៀមក្រំ
ពញាយ៉ាត អង្គកុសត្រក្សាណ បានរៀបចំ
ក្រុងឧត្តម ខ្ពុំនឹកដល់ ខ្វល់មិនណាយ។

* កំពង់ចាម តាមដងទ- ន្លេមេគង្គ
ស្រស់បំព្រង ប៉ងស្នេហ៍ស្និទ ឥតរសាយ
វត្តជីដុះ ខ្សាច់កោះប៉ែន សែនសប្បាយ
ខ្សល់ពីឆ្ងាយ សាយក្លិនចំ- ការកៅស៊ូ ។

* ខេត្តក្រចេះ ល្អវិសេស ព្រៃកកាំពី
វែនសោភី រំដួលផ្កា ស្រុកសំបូរ
ក្រពុំឈូក វត្តសសរ មួយរយឈរ
រលកថ្លរ ជំនោរខ្សល់ បរិសុទ្ធ ។

* ខេត្តស្ទឹងត្រែង ថ្លែងមិនអស់ ស្រស់ល្អឆើត
ស្រុកកំណើត នៃលោកសុិន- ស៊ីសាមុត
និ សេកុង អាណុង្គស្នេហ៍ សែនកំសត់
មិនគួរព្រាត់ ចាត់ស្មាមអ- នុស្សារីយ៍ ។

www.elibraryofcambodia.org

* ឡើងយន្តហោះ ទៅចុះនៅ ដីបានលុង
ឃើញទ្រនុង ដងភ្នំរ័តៈ -នៈគីរី
បីងកន្សែង ថ្លែងវិយោគ ទុក្ខញាំញី
ជាធរណី នៃស្នេងកែវ មរតកជា ។

* ឱ ទឹកដី ឥសានអើយ ខ្ញុំនឹកណាស់
កម្មឱ្យច្រាស់ ព្រាត់ពីដង ដែនបុព្វតា
ពីមណ្ឌល គីរីស្រស់ ជ្រោះប៉ូស្រា
រឿងស្នេហា ម៉ៅសារ៉ែត និងតួចតេង ។

* ព្រះវិហារ ជាដែនដី ប្រវត្តិសាស្ត្រ
ខ្មែរចាំច្បាស់ មិនប្រឌិត ដូចរឿងព្រេង
ប្រាសាទព្រះ វិហារឈរ យ៉ាងទន្ទឹង
ជាតិខ្លះក្លែង ចង់បានជា របស់គេ ។

* ឆ្នាំមួយពាន់ ប្រាំបួនរយ ហុកសិបពីរ
ខ្មែរគ្រប់ទី បានឈ្នះក្តី នៅឡាអេ
ថាប្រាសាទ ព្រះវិហារ ពិតជាកេរ
របស់ខ្មែរ តាំងតែពី បូរាណកាល ។

www.elibraryofcambodia.org

* កំពង់ស្តី ឮចំរៀង បទមនោជ្ញ
ចិត្តសែនខ្វល់ នឹកទៅដល់ ខេត្តកណ្តាល
ខេត្តតាកែវ អ្នកស្បាញ់ហួល ល្អត្រកាល
តេដំណាល និយាយពី ព្រៃកប្បាស ។

* ខេត្តព្រៃវែង ជាកន្លែង សម្បុរណ៍ចាប
ហើរឆក់ឆាប ស៊ីស្រូវច្រាំង ច្រើនក្រៃក្រាស់
ខ្ញុំនចុកខ្លាញ់ ឈឺថាឆ្លាញ់ មាត់ខ្លាំងណាស់
មិនប្រទះ មានសោះឡើយ នៅស្រុកយើង ។

* ខេត្តកំពត មានទឹកឈូ និងឆ្នេរកែប
ឃើញគួរនែប និត្យចិត្តចង ជាចំរៀង
កំពង់សោម ប្រលោមស្នេហ៍ ក្បែរខ្នងនាង
ស្តាប់ចំរៀង មាត់សមុទ្រ ពេលថ្ងៃលិច ។

* ខេត្តកោះកុង អន្លង់ត្រី សមុទ្រធារ
ផ្ទៃគង្គា ត្រាថ្ងៃរះ ភ្ញីដូចពេជ្រ
អ្នកបានឃើញ កោះកុងហើយ ចាំមិនភ្លេច
នឹកជានិច្ច ពេលថ្ងៃលិច សែនស្រណោះ ។

www.elibraryofcambodia.org

* ទឹកដីខ្មែរ គួរខំថែ កុំឱ្យចាត់
តាមបន្ទាត់ ក្រែត្សព្រំដែន ដ៏ច្បាស់លាស់
កុំបណ្តោយ ឱ្យចាត់បង់ ទៀតឱ្យសោះ
គួរស្រណោះ ទឹកដីយើង តូចណាស់ហើយ ។

* យើងមានទឹក យើងមានត្រី ព្រៃព្រឹក្សា
គ្មានជាតិណា សម្បូរណ៌ត្រី ដូចយើងឡើយ
គួរគ្រប់គ្រង ឱ្យហ្មត់ចត់ កុំកន្តើយ
កុំបណ្តោយ ឱ្យហិនហោច ឈើ និង ត្រី ។

* យើងមានស្នូង មានរែងដែក មាសព្រោងព្រាត
មានប្រេងកាត នៅក្នុងចាត ដែនជលស័យ
មានប្រាសាទ ជាងពីរពាន់ ពាសពេញផ្នែ
ជាស្នាដៃ បុព្វបុរស សាងទុកឱ្យ ។

* ទោះបីជា ប្រទេសយើង តូចហើយក្រ
តែវប្បធម៌ យើងរុងរឿង មិនទន់ខ្សោយ
គួរពង្រឹង ផ្នែកទេសចរណ៍ កុំបណ្តោយ
ទៅថ្ងៃក្រោយ យើងមិនខ្សោយ ក្រទៀតទេ ! ។

៣០-០១-០២

ឥឥឥ ឥឥឥ ឥឥឥ

www.elibraryofcambodia.org

១៧- ជម្ងឺហើរព្រេចខាសនា

(ពាក្យ ៥)

* ដុតធូប ផ្សងវាសនា
ឱ្យហោរា ជួយទស្សន៍ទាយ
ដេញលេខតាមទំនាយ
ទាយរកជោគជ័យសើរ ។

* ពេលណាសង្គមខ្មៅ
អួរអាប់ក្តៅក្នុងហឫទ័យ
មានជនខ្មែរ ប្រុសស្រី
ខ្វះរំពៃ ពឹងធូបទៀន ។

* ស្រោចទឹកលើកភាសី
ផ្ចង់ស្មារតីផ្តោតវិញ្ញាណ
សុំជួយឱ្យបានមាន
កុំអត់ឃ្លានដូចសព្វថ្ងៃ ។

* ខ្វះទាយរកសង្ឃរ
ខ្វះព្រាថ្នាស្តារលាភជ័យ
តើឆ្នាំ ពីរពាន់បី
ចោះឆ្នោតថ្មី ជាប់ទៀតទេ ? ។

www.elibraryofcambodia.org

* ខ្ញុះបែបមានសង្ឃឹម
សើចញញឹមស្រស់ជាទ្វេ
ខ្ញុះភ័យខ្លាចចាញ់គេ
អោនមុខខ្មៃមិនចេញស្តី ! ។

១០-០២-០២

ចប់ចប់ ចប់ចប់ ចប់ចប់

www.elibraryofcambodia.org

១៨. ជម្រើសស៊ីជោរ

(ពាក្យ ៣)

* ពាងប្រហុក ទុកយូរទៅ មានទឹកជោរ
ហៀរស្រក់ហូរ ជោរស្លាំងស្លេក មិនហ៊ានសូរ
ដូចអ្នកខ្លះ ស្មានតែខ្លួន នៅក្បិនល្អ
ខំប្រឹងឈរ ឱ្យអ្នកទ្រ បណ្ដោរលេង ។

* ជាតិអ្នកចេះ មិនប្រហែស ចិត្តឱ្យជោរ
មិនដូចគោ ត្រូវគេចាក់ ហាក់កញ្ឆេង
ឬដូចមាន់ ត្រូវកញ្ជ្រោង ចាប់ស៊ីលេង
ព្រោះវង្វេង នឹងសម្រស់ គេបណ្ដោរ ។

* អង្គរបែក លង្វែកចាក់ ធ្លាក់អន្តរាយ
គ្មានអ្វីឆ្ងាយ ក្រៅពីលង់ ក្នុងរោគមោ-
ទៈនៈភាព ភ្លេចប្រុងប្រៀប រៀបជំហរ
ទ័ពចោលជួរ បែកសាមគ្គី ក៏មិនដឹង ? ។

* ខ្មែរឥឡូវ បើនៅតែ លង់ក្នុងជោរ
តង់ធ្លាក់អូរ ថ្ងូរដូចព្រាប មិនចាំប្រឹង
ព្រោះបរិវារ ខ្វល់តែរឿង ជីដំឡឹង
ចេះតែប្រឹង បណ្ដោរថែម ទាល់បះជើង ! ។

www.elibraryofcambodia.org

១៩. ជម្ងឺអែបអប

(ពាក្យ ៤)

* ជាតិអ្នកអែបអប, ចាក់ខ្សែវាយស្រប ខ្សែបឡបឡែមឡឺម
ចាក់ចេកចាក់ស្ករ ពព្រើតពព្រើម ញញើតញញើម
គេមតើមសុំបុណ្យ ។

* គ្មានជំនាញអ្វី ក្រៅពីយកដៃ អោបពងជាទុន
លុតក្រាបដើរទា វារលូនតត្រុន លំនិនផ្គាប់ផ្គុន
សុំបុណ្យចៅហ្វាយ ។

* ត្រេះឆ្វេងត្រេងស្តាំ លាភច្រូលប្រចាំ ផឹកស៊ីសប្បាយ
ពេលណាមិនស្រួល ដកថយចេញឆ្ងាយ លើកដៃ bye ! bye !
ចៅហ្វាយចិត្តជា ។

* ជម្ងឺអែបអប ជម្ងឺរណប ជម្ងឺផ្ទៃល្ងា
ជម្ងឺនេះកប់ ក្នុងសួតកម្ពុជា ពួកក្លួតគ្រាំគ្រា
ដួចជារបេង ។

* សម័យប៉ុលពត សម័យផ្ទោះលោត មហាចិញ្ចែង
ព្រោះរឿងអែបអប វាយស្របស្តាំឆ្វេង សម្លាប់គ្នាឯង
ជិតពីរលាននាក់ ! ។

www.elibraryofcambodia.org

* គួរប្រុងប្រយ័ត្ន រុមគ្នាកំចាត់ ជម្ងឺគ្រោះថ្នាក់
ព្រោះសម័យនេះ ជាសម័យបក្ស ងាយនឹងមរណៈ
បើ បក្សឃ្លេងឃ្លោង ! ។

០៧-០៣-០២

ឥឥឥ ឥឥឥ ឥឥឥ

www.elibraryofcambodia.org

๓๐. ជម្ងឺរលោភសិទ្ធិ

(ពាក្យ ៥)

* ជម្ងឺរំលោភសិទ្ធិ
បើរិះគិតគួរឱ្យខ្លាច
ច្រើនអ្នកមានអំណាច
ចិត្តកោងកាចបែបផ្តាច់ការ ។

* យកអំណាចពីភរិយ្ស
ដែលជាម្ចាស់នៃអាជ្ញា
មកចាក់កាប់ប្រហារ
គ្មានមេត្តារាស្ត្រវិញឡើយ ។

* បុណ្យសំត្តិច្រាក់អំណាច
គួរឱ្យខ្លាចណាស់ព្រះអើយ
បើគេចង់ឈ្នះហើយ
គ្មានអ្វីឡើយប្រឆាំងបាន ។

* អ្នកក្រលិតលង់ខ្លៅ
តែងតែត្រូវគេបំពាន
រងគ្រោះហើយមិនហ៊ាន
ព្រោះតែគ្មានច្រាក់តក្តី ។

www.elibraryofcambodia.org

* ពឹងលើតុលាការ
ដូចទេវតាខ្វាក់ប្រស្រី
ក្រតោងក្រាបដល់ជី
ព្រោះអ្វីៗ ស្រេចតែថា ! ។

១៥-០៣-០២

ឥឥឥ ឥឥឥ ឥឥឥ

www.elibraryofcambodia.org

២១. ជម្ងឺស្លេចព្រលឹង

(ទាក្យ ៥)

* ព្រោះតែរឿងដុល្លារ
មានខេមរាខ្វះភ្ញែចអស់
បែរជាទៅកាប់តាស់
ល្ងចយកអស់រូបចម្លាក់ ។

* ពីក្នុងប្រាសាទជ័យ
ជាស្នាដៃនៃសិល្បៈ
វប្បធម៌ដ៏ឯកអគ្គ
ទៅលួចលាក់លក់ឱ្យគេ ។

* ជួនតាខំកសាង
ជាដំណាងទុកឱ្យខ្មែរ
ឱ្យល្បីឈ្មោះឮកែ
បែរជាខ្មែរខ្វះភ្ញែចឈឹង ។

* ទៅលក់ឱ្យឈ្មួញថៃ
ដែលសឲ្យថ្លៃគេខំប្រឹង
ឱ្យខ្មែរ អស់ព្រលឹង
ស្រួលគេនឹង ធ្វើអី។ ។

www.elibraryofcambodia.org


* វត្ថុថ្មបុរាណ
ដែលជីកបានពីក្នុងដី
សុទ្ធតែមានអម្លែ
ប្រាប់ថាដីខ្មែរពិតៗ ។

* បើយើងគិតតែប្រាក់
ជីកគាស់លក់ ដោយមិនគិត
ឃ្លាទៅតង់អស់ពិត
ឥតមានអ្វីជាភស្តុតាង ។

* ថាដីយើងមានកេរ
ចំណេរទុកជាសំអាង
បែរជាអ្នកជិតខាង
តេមានអាងយ៉ាងច្បាស់លាស់ ។

* លក់បានប្រាក់តិចតួច
គ្រាន់ស្មែចថ្លៃក្រពះ
ឯជាតិរងវិនាស
និរាសអស់ព្រលឹងជាតិ ។

www.elibraryofcambodia.org



លោក តង្គ ប៊ីនឈឿន

ថតពីឆ្នាំ ១៩៨៧ នៅមាត់ស្ទឹងសង្កែ

ឃុំត្នោតកណ្តៀង ស្រុកបាកាន ខេត្តពោធិ៍សាត់

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធីខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្ចៅ យ៉ាតណៃ, ខ្ចៅ សុផល, ខ្ចៅ វិសាល, ខ្ចៅ រ៉ាមុន, ខ្ចៅ ភារដា, ខ្ចៅ ចំរើន និង
ខ្ចៅ ភារី បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ចៅ ពាញ និង ឧបាសិកា ឈរ យឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ស្តេនជា eBook ដោយ ជាន់ រចនា
ខែមេសា ឆ្នាំ២០១៦
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តរទៀត
សូមទិញ ឬជារពីអ្នកនិពន្ធ
ឬបណ្ណាគាដោយផ្ទាល់ដើម្បីគោរព "រក្សារសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគាទេ។

សូមអរគុណ
ខ្ចៅ ឃុនសំរ៉ង
ប្រធានមូលនិធីខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org